# សៀវភៅណែនាំសម្រាប់បុគ្គលិកផ្នែកចំណីអាហាររបស់រដ្ឋវ៉ាស៊ីនតោន



Washington State Department of Health

ភាសាខ្មែរ (Khmer)

# សូមអរគុណចំពោះការដើរតួយ៉ាងសកម្មក្នុងការរក្សាសុវត្ថិភាពចំណីអាហារ។

## ព័ត៌មានក្នុងសៀវភៅណែនាំនេះជួយអ្នកឱ្យចេះរក្សាទុក រៀបចំ និងបម្រើអាហារដោយមានសុវត្ថិភាព។

ចំណេះដឹងផ្នែកសុវត្ថិភាពចំណីអាហារអាចបង្ការជំងឺកើតតាមចំណីអាហារ។ ប្រើប្រាស់អ្វីដែលអ្នកបានរៀនពីសៀវភៅណែនាំនេះនៅកន្លែងធ្វើការ និងនៅផ្ទះ។

**បន្ទាប់ពីអ្នកបានអានសៀវភៅណែនាំនេះ យើងសង្ឃឹមថា អ្នកចងចាំព័ត៌មានជំនួយទាំងនេះ៖**

1. សូមកុំទៅធ្វើការនៅពេលអ្នកឈឺ។
2. លាងដៃរបស់អ្នកឱ្យបានស្អាតល្អ និងនៅពេលដែលចាំបាច់។
3. សូមកុំប៉ះអាហារឆ្អិនស្រាប់ដោយដៃទទេ។
4. រក្សាទុកអាហារឱ្យនៅក្ដៅ ឬត្រជាក់។
5. ចម្អិនម្ហូបនៅសីតុណ្ហភាពត្រឹមត្រូវ។
6. ក្លាស់សេអាហារក្ដៅឱ្យបានឆាប់រហ័ស។
7. រក្សាទុកសាច់ឆៅឱ្យនៅឆ្ងាយពីអាហារផ្សេងទៀត។
8. សម្អាត និងសម្លាប់មេរោគសម្ភារៈធ្វើម្ហូប និងរក្សាកន្លែងរបស់អ្នកឱ្យស្អាត។
9. សូមទិញអាហារពីប្រភព ឬអ្នកផ្គត់ផ្គង់ដែលសុវត្ថិភាពជានិច្ច។
10. បន្តរៀនសូត្រ និងសួរសំណួរអំពីសុវត្ថិភាពចំណីអាហារ។

**សូមចងចាំថា៖** អ្នកជាគ្រឿងផ្សំដ៏សំខាន់បំផុតនៅក្នុងអាហារដែលមានសុវត្ថិភាព!

# មាតិកា


ជំងឺបង្កពីការពុលចំណីអាហារ . . . . . . . . . . . . . . . . . . . . . . . . . . . . . . 1
ការបង្ការជំងឺបង្កពីការពុលចំណីអាហារ . . . . . . . . . . . . . . . . . . . . . . . . . 2
សុខភាពបុគ្គលិកផ្នែកចំណីអាហារ . . . . . . . . . . . . . . . . . . . . . . . . . . . . 3
អ្នកឆាប់រងការវាយប្រហារ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 4
គ្រោះថ្នាក់នៅក្នុងចំណីអាហារ . . . . . . . . . . . . . . . . . . . . . . . . . . . . . 5
ចំណីអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាព ដើម្បីរក្សាសុវត្ថិភាព . . . . . . . . . . . 7
ការលាងដៃ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 8
របៀបលាងដៃរបស់អ្នក . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 9
ការប៉ះដោយដៃទទេ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 10
ការចម្អិនអាហារ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 11
ការប្រើប្រាស់ទែម៉ូម៉ែត្រ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 12
ការរក្សាកម្ដៅ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 13
ការរក្សាភាពត្រជាក់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 14
ការគូសលើកាលបរិច្ឆេទ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 15
ការក្លាស់សេ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 16
ការចម្លងមេរោគ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 18
ប្រភពចំណីអាហារដែលមានសុវត្ថិភាព . . . . . . . . . . . . . . . . . . . . . . . . . . 19
ប្រភេទចំណីអាហារអាល់ឡែហ្ស៊ី . . . . . . . . . . . . . . . . . . . . . . . . . . . . 20
សម្អាត និងសម្លាប់មេរោគ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 21
ការលាងចាន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 22
ការសម្អាតកំអួត និងរាគ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23
ការការពារអាហារ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 24
ការគ្រប់គ្រងសត្វល្អិត . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 25
ការសង្គ្រោះបន្ទាន់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 26


ព័ត៌មាននៅក្នុងសៀវភៅណែនាំនេះ គឺជាសេចក្តីសង្ខេបអំពីក្រមចំណីអាហារលក់រាយរដ្ឋវ៉ាស៊ីនតោន លេខWAC 246-215 ។ ព័ត៌មាននេះមិនមានដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវទាំងអស់នោះទេ។ ប្រើប្រាស់សៀវភៅណែនាំអំពីការបណ្តុះបណ្តាលបុគ្គលិកចំណីអាហារដោយមានការអនុម័ត។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នក។

សៀវភៅណែនាំនេះមានជាទម្រង់ផ្សេងទៀតសម្រាប់ជនពិការ។ សូមទូរសព្ទទៅលេខ 1-800-525-0127 (សម្រាប់ TDD/TTY សូមទូរសព្ទទៅ 711) ដើម្បីដាក់សំណើ។


“សៀវភៅណែនាំសម្រាប់ពលករក្នុងវិស័យចំណីអាហាររបស់រដ្ឋវ៉ាស៊ីនតោន” ដែលត្រូវបានចងក្រងបង្កើតឡើងដោយ នាយកដ្ឋានសុខាភិបាលនៃខោនធី Tacoma-Pierce ទទួលបានអាជ្ញាបណ្ណ ដោយអនុលោមតាម CC BY-NC 4.0

# ជំងឺកើតតាមចំណីអាហារ

មនុស្សមានជំងឺកើតតាមចំណីអាហារ នៅពេលពួកគេបរិភោគអាហារ ដែលមានមេរោគគ្រោះថ្នាក់នៅក្នុងនោះ។ មេរោគអាចចូលទៅក្នុងអាហារបានគ្រប់ពេល។ វាមានសារៈសំខាន់ក្នុងការរៀនសូត្រពីរបៀបគ្រប់គ្រងអាហារ ដោយសុវត្ថិភាព ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺកើតតាមចំណីអាហារ។

## រោគសញ្ញា

ជំងឺកើតតាមចំណីអាហារខ្លះបណ្តាលឲ្យមានរោគសញ្ញាដូចជា៖


រាគ


ក្អួត


គ្រុនក្តៅ

រោគសញ្ញាទាំងនោះអាចធ្ងន់ធ្ងរខ្លាំង ហើយបណ្តាលឱ្យមនុស្សត្រូវទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬស្លាប់បាន។ កុមារ មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ និងអ្នកមានជំងឺរ៉ាំរ៉ៃងាយនឹងឈឺធ្ងន់ជាង។

## នៅផ្ទះ បើសិនអ្នកមានអារម្មណ៍ថា ឈឺ។

កុំធ្វើការទាក់ទងនឹងចំណីអាហារ នៅពេលអ្នកឈឺ។ បុគ្គលិកផ្នែកចំណីអាហារដែលឈឺអាចចម្លងមេរោគទៅអាហារ ផ្ទៃរាបស្មើ សម្ភារៈផ្ទះបាយ និងមនុស្សដទៃទៀត។

**តើអ្នកមាន៖**

| រាគ ឬក្អួត? | ស្បែក ឬភ្នែកឡើងលឿង? |
|---|---|
| សូមកុំធ្វើការនៅជិតអាហារ រហូតទាល់តែអ្នកមិនមានរោគសញ្ញាណាមួយយ៉ាងហោចណាស់ 24 ម៉ោង។. | នៅផ្ទះហើយទៅជួប គ្រូពេទ្យ។ |

## សូមកុំទៅធ្វើការ បើសិនអ្នកមាន៖

- ជំងឺរលាកថ្លើមប្រភេទ A
- ជំងឺបង្កពីបាក់តេរីសាលម៉ូណេឡា (*Salmonella*)
- ជំងឺបង្កពីបាក់តេរីហ្ស៊ីហ្គេឡា (*Shigella*)
- ជំងឺបង្កពីបាក់តេរីអ៊ី.គូលី (*E. coli*)
- ជំងឺបង្កពីវីរុសណូរ៉ូ (Norovirus)

## ជំងឺកើតតាមចំណីអាហារគឺឧស្សាហ៍កើតមានឡើងណាស់។

ជំងឺកើតតាមចំណីអាហារក្នុងមួយឆ្នាំ៖

48,000,000

ការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយសារជំងឺកើតតាមចំណីអាហារក្នុងមួយឆ្នាំ៖

128,000

ការស្លាប់ដោយសារជំងឺកើតតាមចំណីអាហារក្នុងមួយឆ្នាំ៖

3,000

ប្រភពទិន្នន័យ៖ មជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺឆ្លង (CDC)

## របាយការណ៍អំពីជំងឺកើតតាមចំណីអាហារ។




ករណីភាគច្រើនមិនបានរាយការណ៍ទេ។ របាយការណ៍ពីជំងឺកើតតាមចំណីអាហារទៅកាន់ក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នកជាបន្ទាន់។ ពួកគេនឹងជួយធ្វើឱ្យប្រាកដថាមនុស្សច្រើនទៀតមិនធ្លាក់ខ្លួនឈឺ។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# ការបង្ការជំងឺកើតតាមចំណីអាហារ

ការរក្សាទុកចំណីអាហារឱ្យមានសុវត្ថិភាពត្រូវមានផែនការ។ ធ្វើផែនការអំពីរបៀបរក្សាទុក រៀបចំ និងគ្រប់គ្រងចំណីអាហារប្រកបដោយសុវត្ថិភាព។

## ការត្រួតពិនិត្យដ៏សកម្មរបស់អ្នកគ្រប់គ្រង

នេះជាវិធីសាស្រ្តសកម្មមួយសម្រាប់សុវត្ថិភាពចំណីអាហារ។ អ្នកគ្រប់គ្រងបង្កើតដំណើរការបណ្តុះបណ្តាលបុគ្គលិក និងត្រួតពិនិត្យមើល ដើម្បីរក្សាសុវត្ថិភាពចំណីអាហារ។

### ឧទាហរណ៍រួមមាន៖

- ពិនិត្យរកមើលបុគ្គលិកផ្នែកចំណីអាហារដែលមានជំងឺ និងអនុញ្ញាតឱ្យពួកគាត់នៅឆ្ងាយពីគ្រឹះស្ថាន។
- បណ្តុះបណ្តាលបុគ្គលិកឱ្យចេះចម្អិន ទុកឱ្យត្រជាក់ និងរក្សាទុកអាហារដោយមានសុវត្ថិភាព។
- បង្រៀនបុគ្គលិកអំពីពេលណាដែលត្រូវលាងដៃ និងរបៀបលាងដៃ។
- ត្រូវឱ្យប្រាកដថា បុគ្គលិកមិនប៉ះចំណីអាហារដោយដៃទទេ។
- បង្កើតកំណត់ហេតុសីតុណ្ហភាព ហើយនិងពិនិត្យមើលសីតុណ្ហភាពរបស់ចំណីអាហារ។
- សម្រេចចិត្តថា អ្នកណាជាអ្នកវាស់សីតុណ្ហភាព ហើយនិងនៅពេលណា។
- បញ្ជាក់កន្លែងសម្រាប់រៀបចំចំណីអាហារឆៅ។
- ស្វែងរកជំនួយផ្នែកជួសជុល និងជួសជុលអ្វីដែលមិនប្រក្រតី។
- បង្កើតផែនការសម្អាត បន្ទាប់ពីនរណាម្នាក់ក្អួត ឬរាគ។

មនុស្សគ្រប់រូបមានទំនួលខុសត្រូវចំពោះសុវត្ថិភាពចំណីអាហារ ប៉ុន្តែអ្នកត្រូវការនរណាម្នាក់ ដើម្បីធ្វើឱ្យប្រាកដថា វាមានអាទិភាព។

## អ្នកទទួលបន្ទុក៖

គ្រប់គ្រឹះស្ថានផលិតចំណីអាហារត្រូវតែមានអ្នកទទួលបន្ទុក។ ពួកគាត់ជាអ្នកធ្វើឱ្យប្រាកដថា ចំណីអាហារត្រូវបានរៀបចំដោយមានសុវត្ថិភាព។

### អ្នកទទួលបន្ទុករូបនេះ៖

- គឺស្ថិតនៅទីនោះ នៅពេលអ្នកកំពុងធ្វើប្រតិបត្តិការ។
- មានចំណេះដឹង និងការបណ្តុះបណ្តាល ដើម្បីធ្វើឱ្យប្រាកដថា ចំណីអាហារមានសុវត្ថិភាព។
- ផ្ទៀងផ្ទាត់ថា បុគ្គលិកបានអនុវត្តតាមគោលការណ៍សុវត្ថិភាពចំណីអាហារ។
- ធ្វើឱ្យប្រាកដថា គ្មាននរណាម្នាក់ធ្វើការជាមួយចំណីអាហារ នៅពេលពួកគាត់ឈឺ។
- ឆ្លើយសំណួររបស់បុគ្គលិក។

អ្នក គឺជាអ្នកទទួលបន្ទុក ប្រសិនបើអ្នកជា មនុស្សតែម្នាក់គត់នៅក្នុងគ្រឹះស្ថានផលិតចំណីអាហារនោះ។ ត្រូវប្រាកដថា អ្នកទទួលបានការបណ្តុះបណ្តាលក្នុងការរក្សាទុកចំណីអាហារឲ្យមានសុវត្ថិភាព។

## អ្នកគ្រប់គ្រងផ្នែកការពារចំណីអាហារដែលមានវិញ្ញាបនបត្រ

ធ្វើការជាមួយអ្នកគ្រប់គ្រងផ្នែកការពារចំណីអាហារដែលមានវិញ្ញាបនបត្រ។ ពួកគាត់បានទទួលការបណ្តុះបណ្តាលបន្ថែម និងមានវិញ្ញាបនបត្រក្នុងការគ្រប់គ្រងសុវត្ថិភាពចំណីអាហារ។ ពួកគាត់ជាអ្នកជួយអ្នកទទួលបន្ទុក។ ពួកគាត់រួមគ្នាបណ្តុះបណ្តាល ពិនិត្យ និងផ្តល់វិធីបង្ការជំងឺកើតតាមចំណីអាហារ។



**អ្នកទទួលបន្ទុក អាចត្រូវបានគេហៅកាត់ថា PIC។**

# សុខភាពបុគ្គលិកផ្នែកចំណីអាហារ

បុគ្គលិកផ្នែកចំណីអាហារដែលមានសុខភាពល្អ ជួយបង្ការទប់ស្កាត់ជំងឺកើតតាមចំណីអាហារ។ សូមកុំធ្វើការជាមួយចំណីអាហារ បើសិនអ្នកមានអារម្មណ៍ថា ឈឺ។ អ្នកអាចចម្លងមេរោគទៅចំណីអាហារ និងមនុស្សដទៃទៀត។

## សូមកុំទៅធ្វើការ បើសិនអ្នកមាន៖

- ជំងឺរាគរូស ក្អួត ឬខាន់លឿង
- ជំងឺបង្កពីបាក់តេរីសាលម៉ូណេឡា (Salmonella) ជំងឺបង្កពីបាក់តេរីហ្ស៊ីហ្គេឡា (Shigella) ជំងឺបង្កពីបាក់តេរីអ៊ី.គូលី (E. coli) ជំងឺរលាកថ្លើមប្រភេទ A ឬជំងឺបង្កពីវីរុសណូរ៉ូ (Norovirus)
- ឈឺបំពង់កដោយមានគ្រុនក្ដៅ ហើយនិងធ្វើការជាមួយអ្នកងាយរងការវាយប្រហារ



**សូមកុំធ្វើការរហូតទាល់តែបាត់ក្អួត និងរាគរូសរយៈពេលយ៉ាងតិច 24 ម៉ោង។**

សូមហៅទូរសព្ទទៅក្រសួងសុខាភិបាល បើសិនអ្នកបានធ្វើរោគវិនិច្ឆ័យថា មានជំងឺខាន់លឿង ឬជំងឺណាមួយ។

## សូមកុំធ្វើការជាមួយចំណីអាហារ ឬអ្វីដែលប៉ះពាល់ចំណីអាហារ បើសិនអ្នកមាន៖

- របួសឆ្លងមេរោគដែលអ្នកមិនអាចគ្រប ឬរុំផ្ចិតបាន
- កណ្ដាស់ ក្អក ឬហៀរសំបោរ
- ឈឺបំពង់កដោយមានគ្រុនក្ដៅ
- ធ្លាប់បាននៅក្បែរនរណាម្នាក់ដែលមានជំងឺកើតតាមចំណីអាហារ ហើយអ្នកធ្វើការជាមួយអ្នកងាយរងការវាយប្រហារ

**អ្នកអាចធ្វើការងារដូចជា៖**

- យកសំរាមទៅចោល
- បោស
- ជូត
- សម្អាតបន្ទប់ទឹក

ប្រាប់អ្នកទទួលបន្ទុក បើសិនអ្នកបាននៅក្បែរអ្នកដែលមានជំងឺកើតតាមចំណីអាហារ។

## អនាម័យផ្ទាល់ខ្លួន

បុគ្គលិកផ្នែកចំណីអាហារអាចចម្លងមេរោគទៅអាហារ ទោះបីពួកគាត់មើលទៅ មានអារម្មណ៍ថា មានសុខភាពល្អក៏ដោយ។ រក្សាកុំឱ្យមេរោគចូលទៅក្នុងចំណីអាហារ ដោយមានអនាម័យផ្ទាល់ខ្លួនល្អ។

### ការណែនាំសម្រាប់អនាម័យល្អ៖

- កុំធ្វើការជាមួយចំណីអាហារ នៅពេលអ្នកឈឺ។
- លាងដៃរបស់អ្នកឱ្យបានញឹកញាប់។
- ប្រើប្រាស់សម្ភារៈផ្ទះបាយ ឬស្រោមដៃស្អាត ដើម្បីចាប់កាន់អាហារ។
- កាត់ និងសម្អាតក្រចកដៃ។
- ស្លៀកសំលៀកបំពាក់ស្អាត។
- ចងសក់ទៅក្រោយ កាត់ឱ្យខ្លី ឬពាក់សំណាញ់សក់។
- កុំពាក់អៀមផ្ទះបាយ ឬស្រោមដៃទៅបន្ទប់ទឹក។
- រុំកន្លែងដែលមុត រលាក ឬរបួសនៅលើដៃរបស់អ្នកដោយបង់រុំ និងស្រោមដៃប្រើហើយបោះចោល។



ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# អ្នកឆាប់រងការវាយប្រហារ

នរណាៗក៏អាចឈឺដោយសារការបរិភោគអាហារដែរ ប៉ុន្តែមនុស្សមួយចំនួនងាយនឹងរងគ្រោះច្រើនជាងអ្នកផ្សេងទៀត។

## អ្នកទាំងនេះរួមមាន ដូចជា៖


មនុស្សវ័យក្មេង


មនុស្សវ័យចំណាស់


អ្នកមានផ្ទៃពោះ


ប្រព័ន្ធភាពស៊ាំចុះខ្សោយជាមួយនឹងជំងឺដូចជាមហារីក ជំងឺទឹកនោមផ្អែម ឬជំងឺអេដស៍

**សូមយកចិត្តទុកដាក់កាន់តែខ្លាំងឡើង ក្នុងការបម្រើអ្នកឆាប់រងការវាយប្រហារនៅ៖**

- មន្ទីរពេទ្យ
- សាលាមត្តេយ្យ
- មណ្ឌលថែទាំមនុស្សចាស់

## អ្នកឆាប់រងការវាយប្រហារ មិនគួរទទួលទានអាហារដូចជា៖

- សាច់ ត្រី ឬស៊ុតដែលមិនឆ្អិនល្អ
- អយស្ទ័រឆៅ
- សណ្ដែកបណ្ដុះឆៅ
- ទឹកដោះគោ ឬទឹកផ្លែឈើដែលមិនទាន់បានរំងាប់មេរោគ



# គ្រោះថ្នាក់នានានៅក្នុងគ្រឿងបរិភោគ

ចំណីអាហារអាចធ្វើឲ្យពួកយើងធ្លាក់ខ្លួនឈឺបាន បើសិនវាមានផ្ទុកមេរោគ សារធាតុគីមី ឬសារជាតុដែលបង្កគ្រោះថ្នាក់ដល់រាងកាយ។ កាត់បន្ថយហានិភ័យដោយការរៀនពីវិធីគ្រប់គ្រងចំណីអាហារប្រកបដោយសុវត្ថិភាព។

## ការបំពុលតាមបែបជីវសាស្ត្រ

មេរោគដូចជាបាក់តេរី វីរុស និងប៉ារ៉ាស៊ីតអាចធ្វើឱ្យពួកយើងឈឺបាន។ នៅពេលដែលគេនិយាយអំពីជំងឺផ្តាសាយក្រពះ ឬជំងឺគ្រុនផ្តាសាយ 24 ម៉ោង នេះគឺជាជំងឺដែលកើតតាមចំណីអាហារ។ រោគសញ្ញាជាទូទៅគឺ ក្អួត រាគ រមួលពោះ និងក្តៅខ្លួន។ រោគសញ្ញាអាចចាប់ផ្តើមពីរបីម៉ោងក្រោយ ឬច្រើនសប្តាហ៍ក្រោយពីការញ៉ាំ។

### បាក់តេរី



បាក់តេរីអាចឆ្លងមកពីអាហារ ឧបករណ៍ ឬមនុស្ស។ បុគ្គលិកផ្នែកចំណីអាហារត្រូវតែមានការប្រុងប្រយ័ត្ន។ បាក់តេរីរីកលូតលាស់យ៉ាងងាយស្រួលនៅក្នុងចំណីអាហារជាមួយនឹងសារជាតុចិញ្ចឹម សំណើម សីតុណ្ហភាព និងពេលវេលាសមស្រប។ រក្សាទុកអាហារឱ្យក្តៅ ឬត្រជាក់ ធ្វើការឱ្យលឿន ហើយលាងសម្អាតដៃរបស់អ្នក។ ប្រើប្រាស់សម្ភារៈផ្ទះបាយ ឬស្រោមដៃ ដើម្បីធ្វើការជាមួយអាហារឆ្អិនស្រាប់។

### វីរុស



វីរុសមានទំហំតូច ហើយវាត្រូវការវីរុសតែប៉ុន្មានប៉ុណ្ណោះ ដើម្បីធ្វើឱ្យអ្នកឈឺ។ វីរុសដូចជា វីរុសណូរ៉ូ ឬវីរុសជំងឺរលាកថ្លើមប្រភេទ A ឆ្លងរីករាលដាលតាមរយៈ៖

- បុគ្គលិកផ្នែកចំណីអាហារដែលមានជំងឺ
- ការលាងដៃមិនបានស្អាតល្អ
- ការប៉ះអាហារដោយដៃទទេ

វីរុសមួយចំនួនអាចនៅតែមាននៅលើដៃរបស់អ្នក សូម្បីតែបន្ទាប់ពីការលាងដៃបានល្អក៏ដោយ។ អ្នកអាចចម្លងវីរុសបាន ទោះបីជានៅពេលអ្នកមិនមានអារម្មណ៍ថា ឈឺក៏ដោយ។ នេះហើយជាមូលហេតុដែលអ្នកចាំបាច់ត្រូវប្រើប្រាស់សម្ភារៈផ្ទះបាយ ឬពាក់ស្រោមដៃ ដើម្បីរៀបចំអាហារដែលចម្អិនរួចរាល់ហើយ។

### ប៉ារ៉ាស៊ីត



ប៉ារ៉ាស៊ីត គឺជាដង្កូវតូចៗ ឬជំងឺគីស។ ពួកវារស់នៅក្នុងត្រី សាច់ ផលិតផលធម្មជាតិ ឬទឹកកខ្វក់។ សម្លាប់ប៉ារ៉ាស៊ីត ដោយចម្អិនម្ហូបនៅសីតុណ្ហភាពត្រឹមត្រូវ។ ប៉ារ៉ាស៊ីតភាគច្រើនត្រូវបានសម្លាប់ នៅពេលដែលវាកកនៅសីតុណ្ហភាពត្រជាក់ខ្លាំងរយៈពេលយូរ។

## គន្លឹះដើម្បីរក្សាចំណីអាហារដោយសុវត្ថិភាព៖

- កុំធ្វើការនៅពេលអ្នកឈឺ ជាពិសេសនៅពេលក្អួត រាគ ឬក្តៅខ្លួន។
- កុំប៉ះអាហារឆ្អិនស្រាប់ * ដោយដៃទទេរបស់អ្នក។ ប្រើប្រាស់ដង្កៀប សម្ភារៈផ្ទះបាយ ឬស្រោមដៃ។
- រក្សាអាហារឱ្យក្តៅនៅសីតុណ្ហភាព 135°F (57°C) ឬខ្ពស់ជាងនេះ ឬត្រជាក់នៅ 41°F (5°C) ឬទាបជាងនេះ។
- ធ្វើការឱ្យលឿនហើយកុំទុកអាហារចោល។
- ក្លាស់សេ និងកំដៅអាហារឡើងវិញឱ្យបានឆាប់រហ័ស។
- ចម្អិនត្រី និងសាច់ទាំងអស់នៅសីតុណ្ហភាពត្រឹមត្រូវ។
- ប្រើប្រាស់ត្រីដែលត្រូវបានបង្កក ដើម្បីសម្លាប់ប៉ារ៉ាស៊ីតសម្រាប់អាហារឆៅដូចជាស៊ូស៊ី។
- លាងដៃរបស់អ្នកបន្ទាប់ពីប្រើប្រាស់បន្ទប់ទឹក និងមុនពេលចូលផ្ទះបាយ។
- លាងសម្អាតផលិតផលឆៅដោយទឹកស្អាត។
- ទុកអាហារឆៅ និងអាហារឆ្អិនស្រាប់* នៅដាច់ដោយឡែកពីគ្នា។
- សម្អាត និងសម្លាប់មេរោគលើផ្ទៃរាបផ្សេងៗ។
- ប្រើប្រាស់ប្រភពទឹកដែលទទួលបានការអនុម័តឱ្យប្រើ។

*អាហារឆ្អិនស្រាប់អាចបរិភោគបានដោយមិនចាំបាច់លាងសម្អាត ឬចម្អិន ដើម្បីកំចាត់មេរោគ។

## ការបំពុលដោយសារធាតុគីមី

សារធាតុគីមីអាចធ្វើឱ្យអ្នកឈឺ បើសិនពួកវាចូលទៅក្នុងអាហារ។ រក្សាទុកសារធាតុគីមី ដូចជា សាប៊ូ ទឹកសម្អាត និងថ្នាំសម្លាប់មេរោគឱ្យមានសុវត្ថិភាព។ រក្សាទុកសារធាតុគីមី នៅក្រោមអាហារ និងផ្ទៃការងារ។ សារធាតុគីមីមិនគួរអាចស្រក់ចូលទៅក្នុងអាហារ ឬទៅលើផ្ទៃការងារបានទេ។



### ដាក់ស្លាកសារធាតុគីមី និងធ្វើតាមការណែនាំដោយប្រុងប្រយ័ត្ន។

ការពារអាហារនៅពេលអ្នកសម្អាត។ រក្សាទុកតែសារធាតុគីមីដែលអ្នកត្រូវការ។

### ទាក់ទងក្រុមហ៊ុនកំចាត់សត្វល្អិតដែលមានអាជ្ញាប័ណ្ណ ដើម្បីទទួលបានជំនួយសម្រាប់បញ្ហាសត្វល្អិត។

កុំប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតសម្រាប់ប្រើប្រាស់តាមផ្ទះ។

### ប្រើប្រាស់តែសម្ភារៈណាដែលមានសុវត្ថិភាពសម្រាប់ការផ្ទុកអាហារ។

កុំប្រើប្រាស់ថង់ប្រកអីវ៉ាន់ កំប៉ុងកូតស័ង្កសី ឬទង់ដែង។ កុំយកធុងដាក់សារធាតុគីមីមកប្រើប្រាស់ឡើងវិញ។ សារធាតុគីមីអាចជ្រាបចូលទៅក្នុងអាហារ។

## គ្រោះថ្នាក់បែបរូបសាស្ត្រ

គ្រោះថ្នាក់បែបរូបសាស្ត្រ គឺជាវត្ថុនៅក្នុងអាហារ ដែលអាចបណ្តាលឱ្យមានរបួស បើសិនយើងបរិភោគវា។ ឧទាហរណ៍រួមមានកម្ទេចកែវ គ្រឿងអលង្ការ បង់រុំ បំណែកលោហៈ និងក្រចកដៃ។

### គន្លឹះដើម្បីរក្សាអាហារឱ្យមានសុវត្ថិភាពពីគ្រោះថ្នាក់បែបរូបសាស្ត្រ៖



- ត្រូវប្រាកដថា មិនត្រូវឱ្យមានអ្វីមួយធ្លាក់ចូលទៅក្នុងអាហារបានទេ។
- ពិនិត្យមើលឧបករណ៍ឱ្យបានល្អិតល្អន់។ ត្រូវប្រាកដថា មិនមានបំណែកណារលុង ឬខូច។
- បោះចោលប្រាស់ដុសចង្ក្រាន និងសម្ភារៈផ្ទះបាយ បើសិនវាបង្ហាញសញ្ញាអំពីការសឹករេចរឹល។
- កុំពាក់គ្រឿងអលង្ការ។ អ្នកអាចពាក់ចិញ្ចៀនតែមួយវង់ ឬចិញ្ចៀនអាពាហ៍ពិពាហ៍ ហើយពាក់ស្រោមដៃពីលើ។
- ពាក់ស្រោមដៃផ្ទិតក្រចកដែលបានត។
- ប្រើប្រាស់ប្រដាប់ចូកទឹកកកជានិច្ច។ កុំចូកទឹកកកដោយប្រើប្រាស់ កែវ។
- មើលឱ្យបានដិតដល់ចំពោះចំណីអាហារដែលអ្នករៀបចំ។
- ពិនិត្យមើលផ្លែឈើ និងបន្លែដោយប្រុងប្រយ័ត្ន។

# ចំណីអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាព ដើម្បីរក្សាសុវត្ថិភាព

ចំណីអាហារណាក៏អាចបណ្តាលឱ្យកើតជំងឺកើតតាមចំណីអាហារបានដែរ ប៉ុន្តែបាក់តេរីងាយនឹងរីកលូតលាស់ជាងនៅក្នុងអាហារមួយចំនួន។ ចំណីអាហារទាំងនេះត្រូវបានគេហៅថា ចំណីអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាពដើម្បីរក្សាសុវត្ថិភាព (TCS) ។ រក្សាអាហារទាំងនេះឱ្យក្តៅ ឬត្រជាក់ ដើម្បីការពារកុំឱ្យបាក់តេរីរីកលូតលាស់។

**ឧទាហរណ៍អំពីចំណីអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាពដើម្បីរក្សាសុវត្ថិភាព (TCS) មានដូចជា៖**

- សាច់ សាច់បក្សី ត្រី អាហារសមុទ្រ និងស៊ុត
- ផលិតផលទឹកដោះគោ
- តៅហ៊ូ
- សណ្តែកឆ្អិន ដំឡូង បាយ ប៉ាស្តា និងគុយទាវ
- បន្លែ និងផ្លែឈើឆ្អិន
- ផ្លែត្រសក់ស្រូវកាត់រួច
- បន្លែបៃតងហាន់រួច
- ផ្លែប៉េងប៉ោះចិតរួច
- ពន្លក ដូចជាអាល់ហ្វាលហ្វា ឬសណ្តែកបណ្តុះ
- ខ្ទឹមសស្រស់ ឬតិណទេសទុកនៅក្នុងប្រេង
- បីរីករួចស្រាប់




ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

**ពេលវេលា និងសីតុណ្ហភាពធ្វើការជាមួយគ្នា ដើម្បីរក្សាសុវត្ថិភាពចំណីអាហារ។**

រៀនពីរបៀបប្រើប្រាស់ពេលវេលាដើម្បីរក្សាសុវត្ថិភាពចំណីអាហារ។ ធ្វើការជាមួយអ្នកគ្រប់គ្រងផ្នែកការពារចំណីអាហារដែលមានវិញ្ញាបនបត្ររបស់អ្នក សម្រាប់ព័ត៌មានបន្ថែម។

## តំបន់គ្រោះថ្នាក់

បាក់តេរីរីកលូតលាស់បានល្អបំផុតនៅចន្លោះសីតុណ្ហភាពពី 41°F (5°C) ទៅ 135°F (57°C)។ ចន្លោះសីតុណ្ហភាពនេះត្រូវបានគេហៅថា តំបន់គ្រោះថ្នាក់។ ចំណីអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាពដើម្បីរក្សាសុវត្ថិភាព (TCS) ដែលត្រូវបានទុកចោលក្នុងតំបន់ គ្រោះថ្នាក់ អនុញ្ញាតឱ្យពពួកបាក់តេរីរីកលូតលាស់យ៉ាងឆាប់រហ័ស។ បាក់តេរីខ្លះផលិតជាតិពុលដែលធ្វើឱ្យមនុស្សឈឺ។ ជាតិពុលនៅតែមាននៅក្នុងអាហារ ទោះបីជាបានចម្អិនហើយក៏ដោយ។

**គន្លឹះក្នុងការរក្សាចំណីអាហារដោយសុវត្ថិភាព៖**

- ទុកអាហារត្រជាក់នៅសីតុណ្ហភាព 41°F (5°C) ឬត្រជាក់ជាងនេះ។
- ទុកអាហារក្តៅនៅសីតុណ្ហភាព 135°F (57°C) ឬក្តៅជាងនេះ។
- រៀបចំអាហារឱ្យបានរហ័ស។
- ធ្វើការជាមួយអាហារម្តងបន្តិចៗ។
- ដាក់ក្លាស់សេអាហារនៅក្នុងទូទឹកកកឱ្យបានឆាប់រហ័ស។ កុំទុកចំណីអាហារចោលនៅលើតុឱ្យត្រជាក់។
- កម្តៅអាហារឡើងវិញឱ្យបានឆាប់រហ័ស។
- ពិនិត្យសីតុណ្ហភាពចំណីអាហារដោយប្រើទែម៉ូម៉ែត្រ។




ចំណីអាហារដែលត្រូវបានរក្សាទុកនៅក្នុងតំបន់គ្រោះថ្នាក់ អាចនឹងមិនមានសុវត្ថិភាពសម្រាប់ការទទួលទានទេ។ បើសិនអ្នកមានការសង្ស័យ សូមបោះវាចោល។

# ការលាងដៃ

វិធីល្អបំផុតក្នុងការបង្ការជំងឺកើតតាមចំណីអាហារ គឺត្រូវលាងដៃរបស់អ្នក។ មេរោគនៅលើដៃរបស់អ្នកអាចចូលទៅក្នុងចំណីអាហារ នៅពេលដែលអ្នកលាងដៃមិនបានត្រឹមត្រូវ។ អ្នកមិនអាចមើលឃើញមេរោគដោយភ្នែករបស់អ្នកទេ ដូច្នេះអ្នកអាចចម្លងមេរោគបាន ទោះបីជាដៃអ្នកមើលទៅស្អាតក៏ដោយ។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

## លាងដៃរបស់អ្នកឱ្យបានញឹកញាប់។



**លាងដៃរបស់អ្នកបន្ទាប់ពីអ្នក៖**

- ប្រើប្រាស់បន្ទប់ទឹក
- ចូលផ្ទះបាយ
- ប៉ះសាច់ឆៅ អាហារសមុទ្រ សាច់បក្សី ឬស៊ុត
- ប៉ះសក់ ឬមុខរបស់អ្នក
- ក្អក ឬកណ្ដាស់
- កាន់សំរាម ចានកខ្វក់ លុយ ឬសារធាតុគីមី
- ញ៉ាំ ផឹក ឬជក់បារី
- សម្រាក ឬប្រើទូរសព្ទរបស់អ្នក

### ជែល ឬអាល់កុលលាងដៃ

កុំប្រើជែល ឬអាល់កុលលាងដៃ ជំនួសការលាងដៃដោយទឹក និងសាប៊ូ។ អ្នកអាចប្រើជែល ឬអាល់កុលលាងដៃបន្ទាប់ពីលាងដៃដោយទឹក និងសាប៊ូរួច។

លាងដៃនៅរាល់ពេលដែលដៃរបស់អ្នកកខ្វក់។

កាត់ក្រចកដៃ ដើម្បីងាយស្រួលសម្អាត។ ពាក់ស្រោមដៃឱ្យបានជិតល្អ លើក្រចកដៃដែលលាបពណ៌ ឬក្រចកដៃដែលបានត ដើម្បីរៀបចំអាហារ។ ឧទាហរណ៍ ពាក់ស្រោមដៃដើម្បីកូរស៊ុប បើសិនអ្នកមានក្រចកដៃលត។

# របៀបលាងដៃរបស់អ្នក

លាងដៃរបស់អ្នកតែក្នុងឡាបូលាងដៃ។ កុំលាងដៃក្នុងឡាបូសម្រាប់រៀបចំអាហារ ឬឡាបូលាងចាន 3 ខណ្ឌ។ ឡាបូលាងដៃត្រូវតែមានទឹកក្តៅ និងទឹកត្រជាក់ សាប៊ូ និងក្រដាសអនាម័យ ឬម៉ាស៊ីនសម្ងួតដោយប្រើខ្យល់។ កុំបិទឡាបូលាងដៃ ឬទុកអ្វីនៅខាងក្នុងនោះ។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

## អនុវត្តតាមជំហានទាំងនេះ ដើម្បីលាងដៃរបស់អ្នក។

**ចាប់ពីដើមដល់ចប់ អ្នកគួរតែចំណាយពេលយ៉ាងហោចណាស់ 20 វិនាទី។**

1 លាងដៃរបស់អ្នកដោយទឹកក្តៅ។



2 ដាក់លាបសាប៊ូឱ្យបានច្រើន។



3 ត្រដុសដៃរបស់អ្នករយៈពេល 10-15 វិនាទី។ ដុសនៅក្រោមក្រចកដៃ ចន្លោះម្រាមដៃ និងកដៃរបស់អ្នក។




4 លាងដៃរបស់អ្នកជាមួយទឹកដែលកំពុងបង្ហូរ។



5 សម្ងួតដៃរបស់អ្នកដោយក្រដាសអនាម័យ ឬម៉ាស៊ីនសម្ងួតប្រើខ្យល់។



6 បិទទឹកដោយប្រើក្រដាសអនាម័យ។



ប្រើក្រដាសអនាម័យ ឬម៉ាស៊ីនសម្ងួតប្រើខ្យល់ដើម្បីសម្ងួតដៃរបស់អ្នក។
ការសម្ងួតដៃដោយប្រើក្រណាត់ ឬអាវអៀមអាចចម្លងមេរោគទៅដៃរបស់អ្នកវិញ។

# ការប៉ះដោយដៃទទេ

ប្រើប្រាស់ទូរសព្ទ ស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

កុំប៉ះអាហារឆ្អិនស្រាប់ដោយដៃទទេ។ ទោះបីជាលាងដៃស្អាតហើយក៏ដោយ ក៏មេរោគមួយចំនួននៅតែមាននៅលើដៃរបស់អ្នក ហើយអាចចម្លងទៅដល់អាហារបាន។

## អាហារឆ្អិនស្រាប់

អាហារឆ្អិនស្រាប់អាចបរិភោគបានដោយមិនចាំបាច់លាងសម្អាត ឬចម្អិន ដើម្បីកំចាត់មេរោគ។ ឧទាហរណ៍៖

- **ផ្លែឈើ និងបន្លែលាងទឹករួចដែលនឹងមិនត្រូវចម្អិន។**
  ដូចជាផ្លែឈើហាន់ជាចំណិត ញាំសាឡាដ ត្រសក់ត្រាំ និងគ្រឿងលម្អភេសជ្ជៈ។
- **នំដុត ឬប្រភេទនំប៉័ង។**
  ដូចជាចំណិតនំប៉័ង នំខេក ខូឃី និងថូរធីឡាស។
- **អាហារឆ្អិន។**
  ដូចជាភីហ្សា ហាំប៊ឺហ្គឺ ហតដក និងតាកូ។
- **អាហារដែលនឹងមិនត្រូវចម្អិន។**
  ដូចជាសាំងវិច ស៊ូស៊ី សាច់ឆ្អិនស្រាប់ និងទឹកកកសម្រាប់ភេសជ្ជៈ។

### ប្រើប្រាស់ស្រោមដៃអាចបោះចោលបាន ដង្កៀប ប្រដាប់ចូក ក្រដាសទ្រាប់អាហារ ឬសម្ភារៈផ្ទះបាយផ្សេងទៀត ដើម្បីរៀបចំអាហារឆ្អិនស្រាប់។

ឧទាហរណ៍ ប្រើដង្កៀបដើម្បីចាប់ញាំសាឡាដ និងក្រដាសទ្រាប់អាហារដើម្បីខ្ចប់នំខូឃី។ ពាក់ស្រោមដៃដើម្បីធ្វើនំសាំងវិច រៀបចំស៊ូស៊ី ឬចិតបន្លែ។







## ស្រោមដៃ

ដៃកខ្វក់អាចធ្វើឱ្យមានមេរោគនៅខាងក្រៅស្រោមដៃ។ ស្រោមដៃត្រូវបានប្រើប្រាស់ ដើម្បីការពារអាហារពីមេរោគ មិនមែនដើម្បីការពារដៃរបស់អ្នកពីអាហារនោះទេ។

### ចងចាំវិធានទាំងនេះសម្រាប់ការប្រើប្រាស់ស្រោមដៃ៖

- លាងដៃមុនពេលពាក់ស្រោមដៃ។
- ប្រើប្រាស់តែស្រោមដៃដែលប្រើប្រាស់ហើយអាចបោះចោលបាន។
- កុំលាងសម្អាត ឬប្រើស្រោមដៃម្តងទៀត។
- បោះស្រោមដៃចោលបន្ទាប់ពីប្រើប្រាស់រួច។
- ផ្លាស់ប្តូរស្រោមដៃដែលរហែក។
- ផ្លាស់ប្តូរស្រោមដៃដែលអាចនឹងកខ្វក់។
- ដោះស្រោមដៃចេញ ហើយលាងដៃបន្ទាប់ពីធ្វើការជាមួយអាហារឆៅ។
- ប្រើប្រាស់ស្រោមដៃដើម្បីគ្របកន្លែងមុត ដំបៅ ឬបង់រុំ។




★ កាត់បន្ថយការកសំណល់។ បើសិនអ្នកប្រើប្រាស់សម្ភារៈផ្ទះបាយដូចជាដង្កៀប ឬប្រដាប់ចូក អ្នកមិនចាំបាច់ពាក់ស្រោមដៃទេ។

# ការចម្អិនអាហារ

មេរោគដែលបង្កគ្រោះថ្នាក់រស់នៅក្នុងសាច់ឆៅ សាច់បក្សី អាហារសមុទ្រ និងស៊ុត។ ការចម្អិនអាហារបានត្រឹមត្រូវនឹងសម្លាប់មេរោគ និងធ្វើឱ្យអាហារទាំងនេះមានសុវត្ថិភាពក្នុងការបរិភោគ។

## សីតុណ្ហភាពចម្អិនអាហារ

**135°F/ 57°C**

- បន្លែ ផ្លែឈើ គិណទេស និងធញ្ញ ជាតិដែលនឹងត្រូវរក្សាទុកឱ្យនៅក្តៅ។
- អាហារឆ្អិនស្រាប់ខ្ចប់ដូចជា ហតដក និងម្ទេសកំប៉ុង ដែលនឹងត្រូវកំដៅឡើងវិញ និងរក្សាឱ្យនៅក្តៅ។




**145°F/ 62°C**
(រយៈពេល 15 វិនាទី )

- ស៊ុត
- អាហារសមុទ្រ
- សាច់គោ
- សាច់ជ្រូក






**158°F/70°C**
(ភ្លាមៗ)

- ហាំប៊ឺហ្គ័
- សាច់ក្រក




**165°F/ 74°C**
(ភ្លាមៗ)

- សាច់បក្សី (មាន់ មាន់ទួកគី និងទា)
- អាហារដែលមានស្ទួល ឬស្ទួលនៃអាហារ
- ខាសឺរ៉ូល (Casseroles)
- អាហារសមុទ្រឆៅ សាច់ ឬស៊ុត ចម្អិនក្នុងមីក្រូវ៉េវ
- អាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាពដើម្បីរក្សាសុវត្ថិភាព (TCS) ដែលត្រូវបានកម្តៅឡើងវិញ




### ការចម្អិនអាហារដោយមីក្រូវ៉េវ

នៅពេលចម្អិនអាហារសមុទ្រឆៅ សាច់ ឬស៊ុតក្នុងមីក្រូវ៉េវ អ្នកត្រូវចម្អិនឱ្យដល់សីតុណ្ហភាពយ៉ាងតិច 165°F (74°C)។ គ្របអាហារដើម្បីរក្សាសំណើម។ បង្វិល ឬកូរអាហារយ៉ាងហោចណាស់ម្តង នៅពេលចម្អិនអាហារ។ ទុកអាហារឱ្យត្រជាក់ 2 នាទីសិនមុនពេលបរិភោគ។ ប្រើប្រាស់ទែម៉ូម៉ែត្រអាហាររបស់អ្នក។ ពិនិត្យឱ្យបានច្រើនកន្លែងដើម្បីប្រាកដថាអាហារទាំងអស់មានសីតុណ្ហភាពយ៉ាងតិច 165°F (74°C)។

## ការណែនាំដល់អតិថិជន

អាហារមួយចំនួនដូចជាស៊ូស៊ី និងស៊ុត អាចនឹងត្រូវបានបរិភោគឆៅ ឬមិនសូវឆ្អិន។ អាហារទាំងនេះអាចបង្កឱ្យមានជំងឺកើតតាមចំណីអាហារ។ ជូនដំណឹងអតិថិជនអំពីហានិភ័យ ដោយសរសេរការណែនាំដល់អតិថិជននៅលើម៉ឺនុយ។

កុំផ្តល់ចំណីអាហារឆៅ ឬមិនសូវឆ្អិនដល់អ្នកប្រមមនុស្សដែលងាយរងគ្រោះឬដាក់ក្នុងលើម៉ឺនុយសម្រាប់កុមារ។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# ការប្រើប្រាស់ទែម៉ូម៉ែត្រ

អ្នកមិនអាចដឹងថា ម្ហូបឆ្អិនល្អ ហើយឬនៅ ដោយផ្អែកតាមពណ៌របស់វា ឬរយៈពេលដែលវាត្រូវបានចម្អិននោះទេ។ ទែម៉ូម៉ែត្រ គឺជាមធ្យោបាយតែមួយគត់ដើម្បីដឹងថា តើម្ហូបឆ្អិនសព្វ ហើយឬនៅ។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។



រាល់គ្រឹះស្ថានផលិតចំណីអាហារត្រូវតែមាន និងប្រើប្រាស់ទែម៉ូម៉ែត្រអាហារដែលត្រឹមត្រូវ។ វាត្រូវតែមានប្រដាប់ស្ទង់ស្តើងមួយ ហើយអាចអានសីតុណ្ហភាពចន្លោះពី 0°F (-18°C) ទៅ 220°F (104°C)។

## ប្រើប្រាស់ទែម៉ូម៉ែត្រឱ្យបានត្រឹមត្រូវ ដើម្បីទទួលបានសីតុណ្ហភាពត្រឹមត្រូវ។



**លើកអាហារដោយប្រើប្រាស់សម្ភារៈផ្ទះបាយ ឬយកវាចេញពីផ្ទៃចម្អិន។** កុំវាស់សីតុណ្ហភាពអាហារ ពេលវាកំពុងនៅលើផ្ទៃចម្អិន។




**ចាក់ទែម៉ូម៉ែត្រទៅក្នុងផ្នែកក្រាស់បំផុតនៃអាហារ។** សូមរង់ចាំរហូតទាល់តែសីតុណ្ហភាពនៅលើទែម៉ូម៉ែត្រឈប់ប្តូរលេខ។ វាអាចចំណាយពេលដល់ទៅមួយនាទី។




**ពិនិត្យទែម៉ូម៉ែត្ររបស់អ្នក ដើម្បីប្រាកដថា វាវាស់បានត្រឹមត្រូវ។** ដាក់ប្រដាប់ស្ទង់ទែម៉ូម៉ែត្រចូលទៅក្នុងកែវមួយដែលមានដាក់ទឹកកក និងទឹក។ សីតុណ្ហភាពគួរតែស្មើនឹង 32°F (0°C)។ កែតម្រូវ ឬប្តូរទែម៉ូម៉ែត្រ បើសិនវាមិនស្មើនឹង 32°F (0°C) ទេ។




**លាងសម្អាត និងសម្លាប់មេរោគលើទែម៉ូម៉ែត្ររបស់អ្នកជានិច្ច មុន និងក្រោយពេលប្រើប្រាស់។** បន្ទាប់ពីសម្អាតរួច ជូតដោយប្រើប្រាស់ក្រណាត់ដែលបានសម្លាប់មេរោគ ឬប្រើប្រាស់ក្រណាត់អាល់កុល។

# ការរក្សាកម្ដៅ

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

រក្សាទុកចំណីអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាពដើម្បីរក្សាសុវត្ថិភាព (TCS) នៅសីតុណ្ហភាព 135°F (57°C) ឬក្ដៅជាងនេះ រហូតដល់អាហារអាចឱ្យលើកយកមកបរិភោគ ឬទុកឱ្យត្រជាក់ដោយសុវត្ថិភាព។ នេះហៅថា ការរក្សាកម្ដៅ។ ការចម្អិនអាហារមិនសម្លាប់បាក់តេរីទាំងអស់នោះទេ។ បើសិនអាហារឆ្អិនមិនត្រូវបានរក្សាកម្ដៅទេ បាក់តេរីដែលនៅរស់អាចរីកលូតលាស់ និងធ្វើឱ្យមនុស្សឈឺ។

**ប្រើប្រាស់ទែម៉ូម៉ែត្រ ដើម្បីត្រួតពិនិត្យសីតុណ្ហភាពរបស់អាហារក្ដៅ។**




## គន្លឹះដើម្បីរក្សាទុកចំណីអាហារឱ្យនៅក្ដៅ៖

- ត្រូវប្រាកដថាតុកម្ដៅ និងឧបករណ៍កម្ដៅអាហារមានកម្ដៅក្ដៅមុនពេលដាក់អាហារចូល។
- គ្របអាហារ ហើយកូរឱ្យបានញឹកញាប់។
- កុំបន្ថែមអាហារត្រជាក់ទៅលើអាហារក្ដៅ។
- ពិនិត្យសីតុណ្ហភាពអាហារឱ្យបានញឹកញាប់ដោយប្រើប្រាស់ទែម៉ូម៉ែត្រអាហារ។

## ការកម្ដៅឡើងវិញសម្រាប់ការរក្សាកម្ដៅ

អ្នកអាចកម្ដៅអាហារឡើងវិញ ហើយយកវាមកបរិភោគម្ដងទៀត បើសិនវាត្រូវបានទុកឱ្យត្រជាក់ប្រកបដោយសុវត្ថិភាពទេ។ កំដៅអាហារឡើងវិញយ៉ាងលឿនដល់សីតុណ្ហភាព 165°F (74°C) ឬខ្ពស់ជាងនេះក្នុងរយៈពេល 2 ម៉ោង។




- **ប្រើប្រាស់វិធីរហ័សដើម្បីកម្ដៅអាហារឡើងវិញ ដូចជាចង្ក្រាន ឡ ឬមីក្រូវ៉េវ។**
  កុំប្រើប្រាស់តុកម្ដៅ ចង្ក្រានចម្អិនយឺតៗ ឬឧបករណ៍កម្ដៅអាហារ ដើម្បីកម្ដៅអាហារឡើងវិញ។ វានឹងចំណាយពេលយូរពេក និងអនុញ្ញាតឱ្យបាក់តេរីរីកលូតលាស់។
- **កូរអាហារឱ្យបានញឹកញាប់ពេលកំពុងកម្ដៅឡើងវិញ។**
  ពិនិត្យសីតុណ្ហភាពឱ្យបានច្រើនកន្លែង ដើម្បីប្រាកដថា អាហារត្រូវបានកម្ដៅឡើងវិញទាំងស្រុងដល់ 165°F (74°C)។

## ការកម្ដៅឡើងវិញសម្រាប់ការយកមកបរិភោគភ្លាមៗ

បើសិនអ្នកយកអាហារមកបរិភោគភ្លាមៗ អ្នកអាចកម្ដៅវាឡើងវិញឱ្យដល់សីតុណ្ហភាពណាមួយក៏បាន។

ការកម្ដៅឡើងវិញ គឺមានសុវត្ថិភាព លុះត្រាតែអ្នកចម្អិន និងទុកអាហារឱ្យត្រជាក់បានត្រឹមត្រូវ។

# ការរក្សាភាពត្រជាក់

រក្សាអាហារចាំបាច់ត្រូវគ្រប់គ្រងសីតុណ្ហភាពដើម្បីរក្សាសុវត្ថិភាព (TCS) នៅសីតុណ្ហភាព 41°F (5°C) ឬត្រជាក់ជាងនេះ។ នេះហៅថា ការរក្សាភាពត្រជាក់។ បាក់តេរីរីកលូតលាស់យ៉ាងឆាប់រហ័ស នៅពេលដែលអាហារស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់។ ទុកអាហារឱ្យត្រជាក់ក្នុងទូទឹកកក ឬក្លាស់សេទឹកកក។

**ប្រើប្រាស់ទែម៉ូម៉ែត្រ ដើម្បីត្រួតពិនិត្យសីតុណ្ហភាពរបស់អាហារត្រជាក់។**




ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

## គន្លឹះដើម្បីរក្សាទុកចំណីអាហារឱ្យនៅត្រជាក់៖

- បើកទ្វារទូទឹកកក តិចបំផុតតាមដែលអាចធ្វើទៅបាន។
- នៅក្នុងធុងក្លាស់សេ ប្រើផ្ទាំងជ្រៅ និងគម្រប ដើម្បីជួយបិទខ្យល់ត្រជាក់ឱ្យនៅខាងក្នុង។ កុំដាក់អាហារពេញផ្ទាំងពេក។
- បើសិនអ្នកប្រើប្រាស់ទឹកកក សូមដាក់ទឹកកកឱ្យស្មើនឹងកម្រិតអាហារ។ ដាក់ទឹកកកនៅជុំវិញប្រអប់អាហារទាំងស្រុង។
- ពិនិត្យសីតុណ្ហភាពឱ្យបានញឹកញាប់ដោយប្រើប្រាស់ទែម៉ូម៉ែត្រអាហារ។

## ការទុកឱ្យរលាយ

**ទុកអាហារកកឱ្យរលាយដោយសុវត្ថិភាព ដើម្បីការពារកុំឱ្យបាក់តេរីរីកលូតលាស់។**

កុំទុកអាហារកកឱ្យរលាយនៅលើតុ ឬនៅសីតុណ្ហភាពបន្ទប់។

## មានវិធីសុវត្ថិភាពចំនួន 3 ដើម្បីទុកអាហារឱ្យរលាយ៖




**នៅក្នុងទូទឹកកក។** នេះជាវិធីសាស្ត្រដ៏ល្អបំផុត ប៉ុន្តែវាអាចចំណាយពេលយូរបន្តិច។ រៀបចំផែនការទុកជាមុន។



**នៅក្នុងឡាបូសម្រាប់រៀបចំអាហារ។**ត្រាំអាហារនៅក្រោមទឹកត្រជាក់ដែលកំពុងបង្ហូរ។ កុំប្រើប្រាស់ទឹកក្តៅ។ ចម្អិនវាភ្លាមៗ ឬដាក់វានៅក្នុងទូទឹកកកនៅពេលដែលអាហារត្រូវបានរលាយរួចរាល់។



**នៅក្នុងមីក្រូវ៉េវ។** ចម្អិនអាហារភ្លាមៗ បន្ទាប់ពីទុកឱ្យរលាយហើយ។

# ការគូសលើកាលបរិច្ឆេទ

បាក់តេរីមួយចំនួននៅតែរីកលូតលាស់យឺតៗនៅក្នុងអាហារក្នុងទូរទឹកកក។ គូសកាលបរិច្ឆេទលើអាហារ ដើម្បីប្រាកដថា អ្នកមិនទុកវាលើសពី 7 ថ្ងៃ។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

## គូសកាលបរិច្ឆេទអាហារត្រជាក់ដែលបានរក្សាទុកលើសពី 24 ម៉ោង។

ជាពិសេសអាហារដូចជា សាច់ឆ្អិនស្រាប់ ហតដក អាហារសមុទ្រឆ្អើរ ញាំសាឡាដ ទឹកដោះគោ និងឈីសទន់។

**អ្នកមិនចាំបាច់គូសកាលបរិច្ឆេទលើ៖**

- កញ្ចប់អាហារដែលមិនទាន់បានបើក។
- គ្រឿងផ្សំផលិតចេញពីរោងចក្រ ម៉ាយ៉ូណេស និងញាំសាឡាដឆ្អិនស្រាប់ ដូចជាញាំសាឡាដដំឡូងជាដើម។
- ផលិតផលធម្មជាតិទាំងមូលដែលមិនទាន់ចិត ឬហាន់។
- ឈីសរឹងដូចជាផាមេសាន (parmesan) និងអាសៃហ្គូ (asiago)។

## យកអាហារមកជូនអតិថិជន ឬបោះវាចោលក្នុងរយៈពេល 7 ថ្ងៃ បន្ទាប់ពីអ្នកបានបើកវា។

**នៅពេលអ្នកបើក ឬចម្អិនអាហារឆ្អិនស្រាប់ សូមកត់សម្គាល់កាលបរិច្ឆេទភ្លាមៗ។**

ចាប់ផ្តើមពីថ្ងៃដែលអ្នកបើក ឬចម្អិនអាហារនោះហើយបន្ថែម 6 ថ្ងៃ។ ឧទាហរណ៍៖

- បើសិនអ្នកបើកកញ្ចប់អាហារនៅថ្ងៃទី 12 ខែធ្នូ សូមបូកបន្ថែម 6 ថ្ងៃ។ ប្រើប្រាស់ត្រឹមថ្ងៃទី 18 ខែធ្នូ។
- បើសិនអ្នកបើកកញ្ចប់អាហារនៅថ្ងៃសុក្រ សូមប្រើប្រាស់វាត្រឹមថ្ងៃព្រហស្បតិ៍សប្តាហ៍បន្ទាប់។







បើសិនអ្នកផ្សំអាហារដែលមានកាលបរិច្ឆេទផ្សេងៗគ្នា សូមប្រើប្រាស់កាលបរិច្ឆេទអំពីគ្រឿងផ្សំដែលចាស់ជាងគេបំផុត។

**កុំរាប់ថ្ងៃដែលអាហារត្រូវបានបង្កក។**

បិទស្លាកអាហារជាមួយកាលបរិច្ឆេទដែលវាត្រូវបានបង្កក និងកាលបរិច្ឆេទដែលវាត្រូវដាក់ក្នុងទូទឹកកកវិញ។ យកអាហារមកជូនអតិថិជន ឬបោះវាចោលក្នុងរយៈពេលសរុប 7 ថ្ងៃនៅក្នុងទូទឹកកក។ ឧទាហរណ៍៖

- បើសិនអ្នកដាក់អាហារក្នុងទូទឹកកករយៈពេល 2 ថ្ងៃ ហើយបន្ទាប់មកអ្នកបង្កកវា នោះអ្នកអាចដាក់វាក្នុងទូទឹកកករយៈពេល 5 ថ្ងៃទៀត មុនពេលអ្នកត្រូវបោះវាចោល។




**អ្នកអាចគូសកាលបរិច្ឆេទលើអាហារតាមវិធីជាច្រើន។ ប៉ុន្តែវាគួរតែងាយស្រួលសម្រាប់អ្នករាល់គ្នាក្នុងការយល់ និងប្រើប្រាស់។ រក្សាទុកចំណីអាហារទាំងនេះនៅសីតុណ្ហភាព 41°F (5°C) ឬទាបជាងនេះគ្រប់ពេល។**

# ការក្លាស់សេ

អ្នកអាចចម្អិនអាហារ ហើយក្លាស់សេវាទុក ដើម្បីទទួលទាននៅពេលក្រោយ។ វាមានភាពចាំបាច់ណាស់ក្នុងការក្លាស់សេអាហារឱ្យបានឆាប់រហ័សបំផុត។ នៅពេលដែលអាហារចុះត្រជាក់ វាឆ្លងកាត់តំបន់គ្រោះថ្នាក់។ បើសិនវាមិនចុះត្រជាក់យ៉ាងលឿនទេ បាក់តេរីអាចរីកលូតលាស់ និងបង្កឱ្យមានជំងឺកើតតាមចំណីអាហារ។ បាក់តេរីខ្លះបង្កើតជាតិពុល ឬសារធាតុពុលដែលមិនអាចបំបាត់បានដោយការចម្អិន។

ក្លាស់សេអាហារពី 135°F (57°C) ដល់ 41°F (5°C) ក្នុងរយៈពេលសរុប 6 ម៉ោង។ អាហារត្រូវក្លាស់សេដល់សីតុណ្ហភាព 70°F (21°C) ក្នុងរយៈពេល 2 ម៉ោងដំបូង។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

**ការរំលឹក!**

ពាក់ស្រោមដៃ ឬប្រើប្រាស់សម្ភារៈផ្ទះបាយជានិច្ចនៅពេលចាប់កាន់អាហារឆ្អិន។







**ពិនិត្យសីតុណ្ហភាពអាហារ និងធ្វើឱ្យប្រាកដថា វាចុះត្រជាក់យ៉ាងលឿន។**

## មានវិធីជាច្រើនដើម្បីធ្វើឱ្យអាហារចុះត្រជាក់បានលឿន។

### ឆ្នាំងរាក់

ការក្លាស់សេដោយប្រើប្រាស់ឆ្នាំងរាក់មានប្រសិទ្ធភាពសម្រាប់អាហារដូចជាសណ្ដែកដែលលីងឡើងវិញ បាយ ដំឡូង សាច់កិន ពពួកម្ហូបចៀនក្នុងឆ្នាំកាសារ៉ូល ស៊ុប និងទឹកស៊ុប។

**គន្លឹះសម្រាប់ការក្លាស់សេដោយប្រើប្រាស់ឆ្នាំងរាក់៖**

- ដាក់អាហារក្ដៅចូលក្នុងឆ្នាំងរាក់។
- អាហារមិនអាចមានជម្រៅលើសពី 2 អ៊ីញទេ។
- កុំគ្របអាហារ ដើម្បីឱ្យកម្ដៅអាចភាយចេញបានលឿន។
- ដាក់ក្លាស់សេអាហារភ្លាមៗ។
- ដាក់ក្លាស់សេនៅធ្នើរខាងលើ ដើម្បីកុំឱ្យមានរបស់អាចធ្លាក់ចូលទៅក្នុងអាហារដែលមិនបានគ្រប។
- កុំដាក់ត្រួតលើគ្នា ឬគ្របអាហារដែលដាក់ក្លាស់សេ។
- ដាក់ក្លាស់សេនៅក្នុងបន្ទប់ក្លាស់សេ ឬទូទឹកកកធំបំផុតរបស់អ្នក។






ពិនិត្យមើលអាហារដោយប្រើប្រាស់ទែម៉ូម៉ែត្រអាហារ។ អ្នកអាចគ្រប ឬដាក់ឆ្នាំងចូលគ្នា នៅពេលណាដែលសីតុណ្ហភាពអាហារចុះដល់ 41°F (5°C) ឬទាបជាងនេះ។

# ការក្លាស់សេ

## កាត់បន្ថយទំហំសាច់ទាំងមូល។

កាត់សាច់ទាំងមូលដូចជាសាច់អាំង ឬសាច់ជ្រូក ទៅជាបន្ទះកម្រាស់ 4 អ៊ីញ។ កុំប្រើប្រាស់វិធីនេះសម្រាប់សាច់កិន ដូចជាដុំសាច់កិន ឬសាច់អាំងបង្វិល។



### គន្លឹះដើម្បីក្លាស់សេសាច់ដុំធំៗ៖

- ដាក់សាច់ដែលកាត់រួចក្នុងស្រទាប់តែមួយនៅលើថាស។
- ទុកឱ្យមានលំហូរខ្យល់ច្រើន។
- កុំគ្របអាហារ ដើម្បីឱ្យកម្ដៅអាចភាយចេញបានលឿន។
- ដាក់ក្លាស់សេអាហារភ្លាមៗ។
- ដាក់ក្លាស់សេនៅធ្នើរខាងលើ ដើម្បីកុំឱ្យមានអ្វីស្រក់ចូលទៅក្នុងអាហារ។

## ត្រូវប្រាកដថា អាហារចុះត្រជាក់យ៉ាងឆាប់រហ័ស។

ប្រើប្រាស់កំណត់ហេតុសីតុណ្ហភាព។ បោះចោលចំណីអាហារ បើសិនវាចុះត្រជាក់មិនបានលឿនល្មម។




### ក្លាស់សេក្នុងសីតុណ្ហភាពពី៖

- 135°F (57°C) ទៅ 70°F (21°C) ក្នុងរយៈពេល 2 ម៉ោង។
- 135°F (57°C) ដល់ 41°F (5°C) ក្នុងរយៈពេល 6 ម៉ោង។

### គន្លឹះដើម្បីធ្វើឱ្យអាហារចុះត្រជាក់លឿន៖

- ដាក់អាហារក្នុងចានដាក់ទឹកលាយទឹកកក។ ដាក់ទឹកកកព័ទ្ធជុំវិញ អាហារទាំងស្រុង។ កូរឱ្យបានញឹកញាប់។
- ប្រើប្រាស់រំពែកទឹកកក ឬដំបងទឹកកក ដើម្បីកូរអាហារ។
- ប្រើប្រាស់ប្រអប់ស្តើងដែលអនុញ្ញាតឱ្យកម្ដៅភាយចេញ។
- បញ្ចុះសីតុណ្ហភាពអាហារនៅក្នុងឆ្នាំងដែក។ ផ្លាស្ទិច ឬកែវមិនអាចបញ្ចុះសីតុណ្ហភាព អាហារបានលឿនទេ។
- ដាក់ទឹកកកស្អាតចូលទៅក្នុងអាហារ។
- ប្រើប្រាស់ឧបករណ៍ពិសេសដូចជាទូក្លាស់សេរហ័ស (blast chiller)។

## ក្លាស់សេបន្ទាប់ពីរៀបចំរួចរាល់។

អាហារដូចជាសាឡាត់ ប៉េងប៉ោះ ឬអាហារកំប៉ុងអាចចាប់ផ្តើមនៅសីតុណ្ហភាពបន្ទប់។ ក្លាស់សេអាហារដល់សីតុណ្ហភាព 41°F (5°C) ក្នុងរយៈពេល 4 ម៉ោង។




ប្រើប្រាស់គ្រឿងផ្សំដែលបានក្លាស់សេទុកជាមុន នៅពេលដែលអាចធ្វើទៅបាន។

ប្រើប្រាស់ទូរសព្ទស្កែនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# ការចម្លងមេរោគ

សាច់ឆៅ ដូចជាសាច់គោ សាច់បក្សី អាហារសមុទ្រ និងស៊ុត អាចមានផ្ទុកមេរោគ។ ការចម្លងមេរោគកើតឡើងនៅពេលដែលមេរោគនៅក្នុងសាច់ឆៅ ឆ្លងចូលទៅក្នុងអាហារផ្សេងទៀត។ ការបរិភោគអាហារដែលបានឆ្លងមេរោគពីសាច់ឆៅ អាចបណ្តាលឱ្យមានជំងឺកើតតាមចំណីអាហារបាន។

## ទុកសាច់ឆៅនៅដាច់ដោយឡែកពីអាហារផ្សេងទៀត។

### ទុកសាច់ឆៅនៅក្រោមអាហារផ្សេងទៀតនៅក្នុងទូទឹកកក។

ទុកសាច់ឆៅនៅលើធ្នើរតាមលំដាប់នៃសីតុណ្ហភាពចម្អិន។ សីតុណ្ហភាពចម្អិនកាន់តែខ្ពស់ មានន័យថា ធ្នើរកាន់តែទាប។ ទុកត្រីឆៅ និងស៊ុតនៅខ្ពស់ជាងសាច់គោកិន និងសាច់ជ្រូកកិន។ ទុកសាច់មាន់ និងសាច់បក្សីនៅបាតខាងក្រោម។




### ធ្វើសាច់ឆៅនៅឆ្ងាយពីអាហារផ្សេងទៀត។

ប្រើប្រាស់ជ្រុញ និងសម្ភារៈផ្ទះបាយដាច់ដោយឡែក។ ធ្វើសាច់ឆៅ និងផលិតផលធម្មជាតិនៅក្នុងឡាបូដាច់ដោយឡែកពីគ្នា។

## លាងសម្អាត និងសម្លាប់មេរោគ បន្ទាប់ពីអ្នកធ្វើសាច់ឆៅរួចរាល់។



ឈាម ឬទឹកចេញពីសាច់ឆៅអាចប្រឡាក់លើផ្ទៃការងារ និងអាហារផ្សេងទៀត។ លាងសម្អាត និងសម្លាប់មេរោគលើតុ ជ្រុញ ឡាបូ និងសម្ភារៈផ្ទះបាយ បន្ទាប់ពីអ្នកធ្វើសាច់ឆៅរួចរាល់។

លាងដៃបន្ទាប់ពីចាប់កាន់សាច់ឆៅ។

## ការលាងសម្អាតផលិតផលធម្មជាតិ

ផលិតផលធម្មជាតិអាចមានមេរោគ ដី និងថ្នាំសម្លាប់សត្វល្អិតនៅខាងក្រៅ។

### លាងសម្អាតផលិតផលធម្មជាតិមុនពេលអ្នករៀបចំវា ទោះបីជាវានឹងត្រូវបានចម្អិនក៏ដោយ។

លាងជម្រះក្នុងទឹកត្រជាក់ដែលកំពុងបង្ហូរ។ កុំប្រើប្រាស់សាប៊ូ។

លាងសម្អាតផលិតផលធម្មជាតិ ដូចជាផ្លែប៊ឺរ និងផ្លែឪឡឹក ទោះបីជាអ្នកមិនបរិភោគផ្នែកខាងក្រៅក៏ដោយ។ កាំបិតអាចនាំមេរោគ និងដីពីខាងក្រៅទៅខាងក្នុងនៃផលិតផលធម្មជាតិបាន។



### សម្អាត និងសម្លាប់មេរោគលើផ្ទៃការងារ ដែលផលិតផលធម្មជាតិឆៅបានប៉ះពាល់។

ទុកផលិតផលធម្មជាតិដែលមិនទាន់បានលាងសម្អាត នៅដាច់ដោយឡែកពីផលិតផលធម្មជាតិដែលបានលាងសម្អាតរួច។ ទុកផលិតផលធម្មជាតិដែលមិនទាន់លាងសម្អាតនៅខាងក្រោមអាហារឆ្អិនស្រាប់។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# ប្រភពចំណីអាហារដែលមានសុវត្ថិភាព

ចំណីអាហារត្រូវតែនាំចូលមកពីប្រភពមានសុវត្ថិភាព ដែលត្រូវបានអនុម័តដោយក្រសួងសុខាភិបាល។ សូមរៀបចំចំណីអាហារតែនៅក្នុងគ្រឹះស្ថានផលិតចំណីអាហារប៉ុណ្ណោះ។ កុំធ្វើចំណីអាហារនៅផ្ទះ។

ប្រយ័ត្ន អាហារដែលដាក់លក់តាមអនឡាញ។ អាហារមួយចំនួនមិនមានសុវត្ថិភាពទេ។ ពិគ្រោះជាមួយក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នក។

## សត្វទឹកមានសំបកដូចជា ខ្យង ខ្ចៅ លៀស ឬគ្រុំ




សត្វទឹកមានសំបកដូចជាលាសសមុទ្រ អយស្ទ័រ ឬគ្រុំចំពុះទា ត្រូវតែនាំចូលមកពីអ្នកផ្គត់ផ្គង់ដែលមានអាជ្ញាប័ណ្ណ ត្រឹមត្រូវ។

### រក្សាស្លាកអត្តសញ្ញាណដែលភ្ជាប់ជាមួយធុង។

ស្លាកនេះបង្ហាញពីកន្លែងដែលពួកវាត្រូវបានប្រមូល។ កត់ត្រាថ្ងៃដំបូង និងថ្ងៃចុងក្រោយ ដែលសត្វទឹកមានសំបកទាំងនោះត្រូវបានបម្រើជូនអតិថិជន។ រក្សាទុកស្លាករយៈពេល 90 ថ្ងៃ។

## ផ្សិតដកពីក្នុងព្រៃ

ផ្សិតដកពីក្នុងព្រៃក៏ត្រូវការអត្តសញ្ញាណនៃប្រភពផងដែរ។ រក្សាព័ត៌មានអំពីប្រភពចំណីអាហាររយៈពេល 90 ថ្ងៃ។

## ការដឹកជញ្ជូនចំណីអាហារ

ពិនិត្យមើលអាហារជានិច្ច នៅពេលវាដឹកជញ្ជូនមកដល់។

### ត្រូវប្រាកដថា៖

- អាហារមិនខូច ឬផ្អូម។
- កំប៉ុងមិនកំពិត ឬខូចខាត។
- កញ្ចប់ត្រូវបានបិទជិត។
- អាហារត្រជាក់គឺ 41°F (5°C) ឬទាបជាងនេះ។
- អាហារកកត្រូវបានបង្កក។
- អាហារស្ថិតក្នុងស្ថានភាពល្អ។

ទទួលយកការដឹកជញ្ជូនតែនៅពេលដែលអ្នកអាចពិនិត្យមើលអាហារប៉ុណ្ណោះ។

# ប្រភេទចំណីអាហារអាល់ឡឺរហ្ស៊ី

ចំណីអាហារមួយចំនួនអាចបង្កឱ្យមានប្រតិកម្មអាល់ឡឺហ្ស៊ី។ ប្រតិកម្មចំណីអាហារអាចមានលក្ខណៈធ្ងន់ធ្ងរខ្លាំង។ ក្នុងករណីខ្លះ ប្រតិកម្មអាល់ឡឺហ្ស៊ីអាចគំរាមកំហែងដល់អាយុជីវិតទៀតផង។

## ប្រតិកម្មអាល់ឡឺរហ្ស៊ីអាចបណ្ដាលឱ្យ៖

- មានអារម្មណ៍ឈឺផៀបៗ
- ឡើងកន្ទួលលើស្បែក
- ក្អួត
- ហើមមុខ អណ្ដាត ឬបំពង់ក
- ពិបាកដកដង្ហើម
- បាត់បង់ស្មារតី ឬស្លាប់

សូមហៅទូរសព្ទទៅលេខ 911 និងរកជំនួយវេជ្ជសាស្ត្រភ្លាមៗ បើសិនជនណាម្នាក់មានប្រតិកម្មអាល់ឡឺហ្ស៊ី។

## វាមានសារៈសំខាន់ណាស់ ដែលត្រូវដឹងពីគ្រឿងផ្សំដែលគ្រឹះស្ថានរបស់អ្នកប្រើប្រាស់។

អតិថិជនអាចសាកសួរអ្នកអំពីគ្រឿងផ្សំដូច្នេះពួកគេអាចជៀសវាងគ្រឿងផ្សំទាំងនោះបាន។ អ្នកដែលមានអាល់ឡឺហ្ស៊ីត្រូវតែជៀសវាងចំណីអាហារដែលមានជាតុផ្សំនោះ។ សូម្បីតែចំនួនតិចតួចក៏អាចធ្វើឲ្យមនុស្សម្នាក់ឈឺខ្លាំងបានដែរ។

ឧទាហរណ៍ | អ្នកដែលអាល់ឡឺហ្ស៊ីទៅនឹងស៊ុតត្រូវតែ ជៀសវាងនំខេក ប៉ាស្តា និងម៉ាយ៉ូណេស ។

សូមកុំធ្វើការស្មាន។ សាកសួរមេចុងភៅអំពីគ្រឿងផ្សំនៃអាហារ។

### ទុកវាឱ្យនៅដាច់ដោយឡែក។

ប្រាប់មេចុងភៅ បើសិនអតិថិជនរាយការណ៍អំពីអាល់ឡឺហ្ស៊ីចំណីអាហារ។ ស្រោមដៃ សម្ភារៈផ្ទះបាយ ឧបករណ៍ និងផ្ទៃទាំងអស់ អាចផ្ទេរសារជាតុដែលបង្កអាល់ឡឺហ្ស៊ីទៅអាហារផ្សេងទៀត។

## កំពូលធាតុបង្កឱ្យអាល់ឡឺរហ្ស៊ីចំណីអាហារ៖

- ទឹកដោះគោ
- ស៊ុត
- ត្រី
- គ្រាប់ផ្លែឈើ
- ស្រូវសាលី
- សណ្ដែកដី
- សណ្ដែកសៀង
- សត្វទឹកមានសំបកដូចជា ខ្យង ខ្ចៅ លៀស ឬគ្រំ
- ល្ង



ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# សម្អាត និងសម្លាប់មេរោគ

## ការសម្អាត និងការសម្លាប់មេរោគមិនដូចគ្នាទេ។

**ការសម្អាត** ប្រើប្រាស់សាប៊ូ និងទឹកដើម្បីលាងជម្រះចំណីអាហារ ធូលី និងខ្លាញ់ចេញ។

**ការសម្លាប់មេរោគ** ប្រើប្រាស់សារធាតុគីមី ឬកម្ដៅដើម្បីសម្លាប់មេរោគ។

**ទឹកសម្លាប់មេរោគដែលត្រូវបានអនុម័តឱ្យប្រើប្រាស់៖**

- ក្លរីន ប្លីចធ៍ (Chlorine bleach)
- ខ្វាធ័រណារី អាម៉ូញ៉ូម (Quaternary ammonium)
- អ៊ីយ៉ូដ (Iodine)

នៅមានទឹកសម្លាប់មេរោគផ្សេងទៀត។

## អនុវត្តតាមការណែនាំនៅលើស្លាកផលិតផលជានិច្ច។




**នៅពេលលាយទឹកសម្លាប់មេរោគត្រូវវាល់វាជានិច្ច។**
កុំបន្ថែមសាប៊ូ។ សាប៊ូរារាំងទឹកសម្លាប់មេរោគមិនឱ្យសម្លាប់មេរោគបាន។ ទឹកសម្លាប់មេរោគទូទៅ គឺទឹកស្លុយស្យុងធ្វើឱ្យស (bleach) 1 ស្លាបព្រាកាហ្វេ ក្នុងទឹកមួយហ្គាឡុង។




**ពិនិត្យមើលកម្លាំងនៃទឹកសម្លាប់មេរោគ។**
ប្រើប្រាស់បន្ទះតេស្ត ដើម្បីដឹងច្បាស់ថាទឹកសម្លាប់មេរោគ គឺមានកម្លាំងត្រឹមត្រូវ។



**ប្រើទឹកសម្លាប់មេរោគដាច់ដោយឡែកពីគ្នា។**
សម្លាប់មេរោគនៅលើផ្ទៃរាប មុន និងក្រោយពេលអ្នកធ្វើសាច់ឆៅ និងអាហារឆ្អិនស្រាប់។



**ទុកក្រណាត់ជូតនៅក្នុងទឹកសម្លាប់មេរោគ។**
ការធ្វើបែបនេះរារាំងមេរោគមិនឱ្យរីកលូតលាស់នៅលើក្រណាត់។



**ធ្វើទឹកសម្លាប់មេរោគឱ្យបានញឹកញាប់។**
វាលែងមានប្រសិទ្ធភាព នៅពេលទុកវាកាន់តែយូរ។ ប្ដូរទឹកសម្លាប់មេរោគ បើសិនវាកខ្វក់ ឬល្អក់។

លាងសម្អាត លាងជម្រះ និងសម្លាប់មេរោគនៅលើសម្ភារៈផ្ទះបាយ និងឧបករណ៍បន្ទាប់ពីប្រើប្រាស់រួច។

ប្រើប្រាស់ទូរសព្ទ ស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# ការលាងចាន

លាងសម្អាត និងសម្លាប់មេរោគចាន សម្ភារៈផ្ទះបាយ និងឧបករណ៍។ លាងចានដោយដៃនៅក្នុងឡាបូលាងចាន 3 ខណ្ឌ ឬដោយប្រើប្រាស់ម៉ាស៊ីនលាងចាន។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

## អនុវត្តតាមជំហានទាំងនេះ៖

1. កោសអាហារ និងខ្លាញ់ដែលនៅសល់ចូលក្នុងធុងសំរាម។
2. លាងសម្អាតជាមួយទឹកសាប៊ូក្តៅ។
3. លាងជម្រះជាមួយទឹកស្អាតដែលក្តៅ។
4. ត្រាំក្នុងទឹកសម្លាប់មេរោគ។ ប្រើប្រាស់បន្ទះតេស្តដើម្បីដឹងច្បាស់ថាទឹកសម្លាប់មេរោគគឺមានកម្លាំងត្រឹមត្រូវ។
5. សម្ងួតដោយខ្យល់។ កុំប្រើប្រាស់កន្សែង។ កន្សែងអាចចម្លងមេរោគបាន។



### គន្លឹះក្នុងការប្រើប្រាស់ម៉ាស៊ីនលាងចាន៖

- កោសអាហារ និងខ្លាញ់ដែលនៅសល់ចូលក្នុងធុងសំរាម។
- ម៉ាស៊ីនលាងចានប្រើប្រាស់កំដៅ ឬសារធាតុគីមីដើម្បីសម្លាប់មេរោគ។ ប្រើប្រាស់បន្ទះតេស្ត ដើម្បីប្រាកដថាវាសម្លាប់មេរោគបានត្រឹមត្រូវ។
- សម្ងួតចានដោយប្រើប្រាស់ខ្យល់ឱ្យស្ងួតមុនពេលអ្នកយកវាទៅទុក។

## តុរៀបចំចំណីអាហារ និងឧបករណ៍ធំៗ

មិនមែនគ្រប់អ្វីៗទាំងអស់អាចដាក់ចូលក្នុងម៉ាស៊ីនលាងចាន ឬឡាបូលាងចាន 3 ខណ្ឌនោះទេ។

**ជំហានក្នុងការសម្អាត និងសម្លាប់មេរោគលើឧបករណ៍ផ្សេងទៀត៖**

- ដុសដោយប្រើប្រាស់ទឹកសាប៊ូក្តៅ។
- លាងជម្រះជាមួយទឹកស្អាត។
- ជូតទឹកសម្លាប់មេរោគដោយប្រើប្រាស់ក្រណាត់ស្អាត។
- ទុកឱ្យស្ងួតដោយខ្យល់។

សម្អាត និងសម្លាប់មេរោគឱ្យបានញឹកញាប់។

សម្អាតផ្ទៃដែលប៉ះអាហាររៀងរាល់ 4 ម៉ោងម្តងៗ។ កុំរង់ចាំរហូតដល់ចុងពេលឈប់ធ្វើការងារ។

# ការសម្អាតកំអួត និងរាគ

ការលាងសម្អាតកំអួត និងរាគ គឺខុសពីការសម្អាតធម្មតា។ អ្នកអាចឈឺ ឬចម្លងជំងឺទៅអ្នកដទៃ បើសិនអ្នកមិនបានសម្អាតតាមវិធីត្រឹមត្រូវ។

**គ្រឹះស្ថានផលិតម្ហូបអាហារត្រូវមានបែបបទជាលាយលក្ខណ៍អក្សរ។**

បុគ្គលិកផ្នែកចំណីអាហារត្រូវតែដឹង និងអនុវត្តតាមបែបបទទាំងនេះ ដើម្បីការពារកុំឱ្យមេរោគរីករាលដាលដល់មនុស្ស ឧបករណ៍ ឬអាហារ។

## សម្អាតកំអួត និងរាគឱ្យបានឆាប់រហ័ស។

**ផែនការល្អរួមមានចំណុចដូចខាងក្រោម៖**

1. នាំអតិថិជន និងបុគ្គលិកចេញពីកន្លែងនោះ។
2. ឃាំងកន្លែងនោះ មិនឱ្យមនុស្សចូល។
3. ពាក់ស្រោមដៃប្រើតែម្តង ម៉ាស់ ចង់ស្រោបស្បែកជើង និងសំលៀកបំពាក់ប្រើតែម្តង។
4. ជូតដោយប្រើប្រាស់ក្រដាសអនាម័យ ហើយដាក់ចូលក្នុងថង់សំរាម។
5. ប្រើប្រាស់ទឹកសាប៊ូដើម្បីលាងសម្អាត។
6. សម្លាប់មេរោគជាមួយថ្នាំសម្លាប់មេរោគដែលបានអនុម័តឱ្យប្រើប្រាស់។
7. បោះចោលអាហារ និងវត្ថុដែលអាចចោលបាននៅកន្លែងនោះ។
8. មេរោគអាចចម្លងបានឆ្ងាយ។ សម្អាត និងសម្លាប់មេរោគឧបករណ៍ និងសម្ភារៈផ្ទះបាយដែលស្ថិតក្នុងចម្ងាយ 25 ហ្វីត (7.62 ម៉ែត្រ)។
9. បោះចោល ឬសម្លាប់មេរោគវត្ថុដែលបានប្រើប្រាស់ដើម្បីសម្អាត។ ចោលទឹកសម្លាប់មេរោគ។
10. យកសំរាមទៅចោលនៅកន្លែងចាក់សំរាមភ្លាមៗ។
11. លាងដៃ និងដើមដៃឱ្យបានស្អាតបន្ទាប់ពីនោះ។
12. ទៅផ្ទះហើយងូតទឹក បើសិនអាចធ្វើទៅបាន។

បើសិនបុគ្គលិកផ្នែកចំណីអាហារឈឺ សូមបញ្ជូនពួកគេទៅផ្ទះវិញ រហូតទាល់តែពួកគេមិនមានរោគសញ្ញារយៈពេល 24 ម៉ោង។

ជៀសវាងឱ្យបុគ្គលិកផ្ទះបាយជាអ្នកសម្អាត នៅពេលអាចធ្វើទៅបាន។

## ជ្រើសរើសថ្នាំសម្លាប់មេរោគដែលត្រឹមត្រូវ។

- ថ្នាំសម្លាប់មេរោគគឺខុសគ្នាពីទឹកសម្លាប់មេរោគ។
- កុំប្រើប្រាស់ទឹកសម្លាប់មេរោគសម្រាប់ប្រើប្រាស់ក្នុងផ្ទះបាយ។
- ជ្រើសរើសថ្នាំសម្លាប់មេរោគដែលអាចសម្លាប់វីរុសណូរ៉ូបាន។
- ធ្វើតាមការណែនាំនៅលើស្លាក។



# ការការពារអាហារ

វាមានសារៈសំខាន់ណាស់ក្នុងការការពារអាហារពីការចម្លងមេរោគ។ ការញ៉ាំ ការផឹក ការជក់បារី ឬរបស់របរផ្ទាល់ខ្លួន អាចចម្លងមេរោគដល់អាហារបាន។

**គន្លឹះដើម្បីការពារអាហារ៖**

- ញ៉ាំ ឬផឹកនៅឆ្ងាយពីកន្លែងរៀបចំអាហារ និងអាហារ។
- កុំជក់បារី វេប ឬប្រើប្រាស់ថ្នាំជក់នៅក្នុងផ្ទះបាយ។
- ផឹកទឹកពីដបដែលបានគ្របជិត។ ទុកវានៅកន្លែងដែលវាអាចមិនកំពប់លើអាហារ ឬផ្ទៃការងារ។
- ចងសក់ទៅក្រោយ កាត់ឱ្យខ្លី ឬពាក់សំណាញ់សក់។
- កុំពាក់គ្រឿងអលង្ការ។ អ្នកអាចពាក់ចិញ្ចៀនតែមួយវង់ ឬចិញ្ចៀនអាពាហ៍ពិពាហ៍ ហើយពាក់ស្រោមដៃពីលើ។
- ទុករបស់របរផ្ទាល់ខ្លួនដូចជាទូរសព្ទដៃ ឬអាវធំ ឱ្យឆ្ងាយពីកន្លែងរៀបចំអាហារ។
- ទុកតែថ្នាំដែលចាំបាច់ប៉ុណ្ណោះ នៅក្នុងគ្រឹះស្ថានផលិតចំណីអាហារ។
- ដាក់ស្លាកសម្គាល់ថ្នាំ។ ទុកវាឱ្យឆ្ងាយពីអាហារ និងកន្លែងរៀបចំចំណីអាហារ។
- ទុកថ្នាំដែលត្រូវក្លាស់សេក្នុងទូទឹកកក ក្នុងប្រអប់ដែលមិនលេចធ្លាយ។ ដាក់ស្លាកសម្គាល់លើប្រអប់នោះ។
- ដាក់កំណត់លើអាហារផ្ទាល់ខ្លួន។ ដាក់ស្លាកសម្គាល់ និងទុកវានៅកន្លែងណាដែលមិនអាចចម្លងមេរោគដល់អាហាររបស់អតិថិជន។

លាងដៃរបស់អ្នកបន្ទាប់ពីកាន់របស់របរផ្ទាល់ខ្លួន។

## ការពារអាហារនៅកន្លែងចាប់ញ៉ាំសាឡាដ និងអាហារប៊ូហ្វេ។

**ផ្តល់នូវ៖**

- វែកស្លាបព្រាដាច់ដោយឡែកសម្រាប់មួបនីមួយៗ។
- លាងសម្អាតចានសម្រាប់ការដើរទៅចាប់ញ៉ាំសាឡាដ ឬអាហារប៊ូហ្វេនីមួយ។
- ផ្ទាំងការពារកណ្តាស់។
- បុគ្គលិកម្នាក់ជាអ្នកត្រួតពិនិត្យអាហារ។



ការពារអាហារដែលអតិថិជនបម្រើដោយខ្លួនឯង។ ប្រើប្រាស់ឧបករណ៍បញ្ចេញគ្រឿងទេស ឬកញ្ចប់សម្រាប់ប្រើប្រាស់តែម្តង។

## មិនត្រូវយកអាហារនៅសល់មកធ្វើឡើងវិញទេ។

បោះចោលអាហារដែលអតិថិជនទុកចោល ដូចជាចូជីឡាស ឬនំប៉ុងវែង។ អ្នកអាចយកអាហារនៅសល់មកបម្រើឡើងវិញសម្រាប់តែអាហារដែលមិនទាន់បានបើក និងអាហារវេចខ្ចប់ ដូចជានំប្រៃ ឬស្ករ។

## រក្សាអាហារឱ្យមានសុវត្ថិភាព។

- កុំទុកអាហារចោលនៅខាងក្រៅ។
- ចាក់សោទូទឹកកកដែលមិនមានអ្នកចាំមើល និងកន្លែងផ្ទុកអីវ៉ាន់។
- ត្រូវប្រុងប្រយ័ត្នជានិច្ច។ រាយការណ៍ភ្លាមៗអំពីការប៉ះពាល់លើចំណីអាហារដែលអាចកើតមាន។

# ការគ្រប់គ្រងសត្វល្អិត

សត្វ ល្អិតចង្រៃដូចជារុយ កន្លាត និងកណ្ដុរជាភ្នាក់ងារចម្លងមេរោគ។



**កុំឱ្យសត្វ ល្អិតចង្រៃចូលៈ។**

បិទទ្វារ និងបង្អួចជានិច្ច ឬដាក់របាំងការពារ។ បិទរន្ធដែលសត្វ ល្អិតចង្រៃអាចចូលបាន។



**ប្រើប្រាស់ធុងសំរាមដែលមានគម្របបិទជិត។**

រក្សាកន្លែងដាក់សម្រាមឱ្យស្អាត។



**លាងសម្អាតឱ្យបានទៀងទាត់ និងគ្របចំណីអាហារជានិច្ច។**

សត្វ ល្អិតតែងតែដើរស្វែងរកអាហារ។ រក្សាកន្លែងដូចជាកម្រាលឥដ្ឋ និងជញ្ជាំងឱ្យស្អាត និងស្ងួត។ បើសិនសត្វ ល្អិតចង្រៃមិនអាចរកអ្វីស៊ី ឬផឹកបានទេ ជាធម្មតាពួកវានឹងមិននៅឡើយ។



**រកមើលសញ្ញានៃសត្វ ល្អិតចង្រៃដូចជាលាមក ឬការវេចខ្ចប់ដែលត្រូវបានកកេរ។**

បើសិនអ្នកមានបញ្ហាសត្វ ល្អិតចង្រៃ សូមទាក់ទងអ្នកឯកទេសដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។ កុំប្រើប្រាស់ថ្នាំសម្លាប់សត្វ ល្អិតនានាសម្រាប់ប្រើប្រាស់តាមផ្ទះ។

វាងាយស្រួលជាងក្នុងការការពារសត្វ ល្អិតចង្រៃមិនឱ្យចូលមកក្នុងជាជាងការកម្ចាត់ពួកវា។

ប្រើប្រាស់ទូរសព្ទស្កែនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

# ស្ថានភាពបន្ទាន់

ស្ថានភាពមួយចំនួនធ្វើឱ្យវាមិនមានសុវត្ថិភាពក្នុងការរៀបចំ ឬបម្រើអាហារ។ អ្នកអាចនឹងត្រូវបិទហាងរហូតទាល់តែបញ្ហាត្រូវបានដោះស្រាយ។

## សូមទាក់ទងមកក្រសួងសុខាភិបាលដើម្បីទទួលបានជំនួយលើ៖

- ការដាច់ចរន្តអគ្គិសនី
- មិនមានទឹកក្តៅ ឬគ្មានទឹកទាល់តែសោះ
- ការផុសទឹកលូមកលើ
- អគ្គីភ័យ
- ទឹកជំនន់
- ទូទឹកកក ឬបន្ទប់ក្លាស់សេមិនធ្វើឱ្យអាហារត្រជាក់
- ឧបករណ៍សំខាន់មិនដំណើរការ
- ការបំពុលដោយសារធាតុគីមី
- ការផ្ទុះឡើងនៃជំងឺកើតតាមចំណីអាហារដែលអាចកើតមានឡើង
- បុគ្គលិកដែលក្អួត ឬរាគនៅកន្លែងធ្វើការ
- អ្វីៗដែលធ្វើឱ្យមានភាពពិបាកក្នុងការរៀបចំចំណីអាហារដោយសុវត្ថិភាព




## បន្ទាប់ពីស្ថានភាពបន្ទាន់ អាហារប្រហែលជាមិនមានសុវត្ថិភាពសម្រាប់ការបម្រើជូនអតិថិជនទេ។

ពិនិត្យមើលអាហារ។ បោះវាចោលនៅពេលវា៖

- ត្រូវបានបំពុល
- បានកម្តៅលើសពី 41°F (5°C)
- ក្លាស់សេនៅក្រោម 135°F (57 °C)

បើសិនអ្នកមានការសង្ស័យ សូមបោះវាចោល។

ប្រើប្រាស់ទូរសព្ទស្កេនកូដ QR ដើម្បីមើលវីដេអូតាមអនឡាញ។

ក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នក គឺជាដៃគូរបស់អ្នកក្នុងការរក្សាសុវត្ថិភាពចំណីអាហារ។ សូមទូរសព្ទទៅពួកគេនៅពេលអ្នកមានសំណួរអ្វីមួយ។

## សូមស្វាគមន៍មកកាន់ក្រុមការងាររក្សាសុវត្ថិភាពចំណីអាហារនៅរដ្ឋវ៉ាស៊ីនតោន។

បានបង្កើតឡើងដោយកិច្ចសហប្រតិបត្តិការជាមួយក្រសួងសុខាភិបាលខោនធី Tacoma-Pierce។